ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ៖ ២១៤
ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០១២
សាលដីកា
លេខ៖ ៥៨៦ "ង"
ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣។

## សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

## ក្រឡាបញ្ជី

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទ៖** អ្នកស្រី [redacted] **សារ៉ុត** (ចុងបណ្តឹងសាទុក្ខ) អាយុ ៦៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

**ចុងចម្លើយ៖** អ្នកស្រី [redacted] **យុន** (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៧៦ឆ្នាំ ជាតិខ្មែរ មុខរបរជាង មានទីលំនៅសព្វថ្ងៃនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

**<u>អំពីវិវាទ</u>៖ ប្តឹងសុំគ្រប់គ្រងដីទំនាស់ទំហំ ២៩៩ម$^2$**



Scanned with CamScanner

## អំពីអង្គហេតុ និង ចំណុចវិវាទ:

### ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ របស់ដើមចោទឈ្មោះ [redacted] សារ៉ុត បានប្តឹងទាមទារសុំអោយតុលាការចេញសាលក្រមសំរេច សុំគ្រប់គ្រងលើដីទំនាស់ទំហំ ២៩៩ម$^2$ ជាកម្មសិទ្ធិមានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន , ខាងត្បូងទល់ឈ្មោះ [redacted] សោភា ផ្លូវជាតិលេខ ៥ ខាងកើតទល់ឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] សោភា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង សុំឱ្យឈ្មោះ [redacted] យុន រុះរើផ្ទះចេញពីដីទំនាស់ អោយចុងចម្លើយជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ដោយមូលហេតុថា នៅក្នុងឆ្នាំ ១៩៨៦ ខ្លួនបានទិញដីពីឈ្មោះ [redacted] សារឿន ដែលមានទំហំ ២៩៩ម$^2$ ក្នុងតម្លៃ ១០.០០០រៀល លុះដល់ឆ្នាំ ១៩៨៧ ឈ្មោះ [redacted] យុន បានសុំខ្លួនស្នាក់នៅបណ្តោះអាសន្នទំរាំដល់ថ្ងៃស្លាប់ ដោយគាត់មិនហ៊ានរស់នៅលើដីកម្មសិទ្ធិរបស់គាត់ដែលនៅពីក្រោយដីរបស់ខ្លួន ដោយបារម្ភខ្លាចក្រែងមានការឈឺថ្កាត់យប់ព្រលប់ ព្រោះគ្មានកូនចៅមើលថែទេ ។ លុះដល់ឆ្នាំ ១៩៨៩ ខ្លួនបានធ្វើពាក្យកាន់កាប់ដីទំនាស់ ព្រមទាំងដីកម្មសិទ្ធិរបស់ខ្លួនសរុបទាំងអស់ ៨០០ម$^2$ ។ ពេលនោះខ្លួនមិនបានចាប់អារម្មណ៍ថាឈ្មោះ [redacted] យុន បានធ្វើពាក្យសុំប្រកាសកាន់កាប់ដីទំនាស់នេះ ឬអត់ទេ ខ្លួនក៏ចេះតែអោយគាត់រស់នៅបន្តជាបណ្តោះអាសន្ន។ ក្រោយមកខ្លួនបានអោយឈ្មោះ [redacted] យុន ចេញពីដីទំនាស់ ស្រាប់តែឈ្មោះនេះមិនព្រមចាកចេញ ទើបខ្លួនប្តឹងមកតុលាការតែម្តង។

**បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ១៩"ង" ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង សំរេច :**

១-តម្កល់សេចក្តីសំរេចលេខ ០១៤ គសជ/សសរ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់គណៈ-កម្មការសុរិយោដីថ្នាក់ជាតិ ទុកជាបានការ លើកលែងតែចំណុចទី ១ ដែលសំរេចអោយភាគីចុងបណ្តឹងរុះរើរោងជួសជុលម៉ូតូចេញពីដីទំនាស់នោះ ត្រូវធ្វើការកែប្រែដូចតទៅ:-

ក-រក្សាសិទ្ធិក្នុងការប្រើប្រាស់រោងជួសជុលម៉ូតូនោះដល់ដើមចោទជាបណ្តោះអាសន្ន រហូតមានការជូនដំណឹងឱ្យរុះរើពីអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលដៅអភិវឌ្ឍន៍ ឬពង្រីកផ្លូវដើម្បីជាប្រយោជន៍សាធារណៈណាមួយនៅតំបន់នោះ។

ខ-បង្គាប់អោយឈ្មោះ [redacted] សារ៉ុត ទុកផ្លូវចេញចូលប្រវែង ២ម នៅផ្នែកខាងលិចដីសម្រាប់អោយចុងចម្លើយឈ្មោះ [redacted] យុន និង ប្រជាពលរដ្ឋនៅក្បែរនោះ ឆ្លងកាត់ទៅផ្លូវជាតិលេខ ៥។

២-បង្វិលចំណែកបណ្តឹងរបស់ដើមចោទសុំគ្រប់គ្រងដីទំហំ ១០១ម$^2$ និង ចំណែកបណ្តឹងតបរបស់ចុងចម្លើយសុំគ្រប់គ្រងដីទំហំ ១៥០ម២ ទៅអោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីដោះស្រាយតាមសមត្ថកិច្ច។

៣-ច្រានចោលការទាមទាររបស់ចុងចម្លើយក្នុងបណ្តឹងតប ត្រង់ចំណុចទាមទារជម្ងឺចិត្តចំនួន៥.០០០



Scanned with CamScanner

ដុល្លាអាមេរិក( ប្រាំពាន់) ទាំងស្រុង។

៤-ប្រាក់ប្រដាប់ក្តីនៅក្នុងរឿងនេះជាបន្ទុករបស់គូភាគីចំនួនពាក់កណ្តាលម្នាក់។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] យុន ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ១១៨ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១"ក្រ.សេ" ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍សំរេច :**

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ របស់មេធាវី ប៊ុន រិទ្ធី តំណាងដោយអាណត្តិរបស់ចុងចម្លើយ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៩(ង) ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបាត់ដំបងទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ ចុងចម្លើយ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២។

បើកសិទ្ធិអោយប្តឹងសាទុក្ខក្នុងអំឡុងពេលមួយខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] យុន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២១៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល។*

**ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u> :**

**ក្រឡាបញ្ជីអានសារណា [redacted] យុន**

**ឈ្មោះ [redacted] សារ៉ុត** ធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនសុំដី ១០១ម$^2$ គ្រប់គ្រងវិញ ព្រោះគាត់សន្យាថាពេលអស់បុណ្យ គាត់ប្រគល់អោយខ្លួនវិញ ចំពោះដីទំហំ ១៩៨ម$^2$ ខ្លួនសុំគ្រប់គ្រងបណ្តោះអាសន្ន បើរដ្ឋត្រូវការពេលណា ខ្លួនសុខចិត្តប្រគល់ជូនរដ្ឋវិញ។ ដោយឡែកឈ្មោះ [redacted] យុន មានដីនៅពីក្រោយដីខ្លួន ហើយនៅក្នុងឆ្នាំ ១៩៨៧ គាត់បានមកសុំខ្លួនសង់ផ្ទះទន្ទឹមខ្លួនរស់នៅបណ្តោះអាសន្ន ដោយសន្យាថាបើគាត់ស្លាប់ពេលណា អោយខ្លួនយកវិញចុះ។

**លោក [redacted]** មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា :ចម្លើយរបស់ [redacted] សារ៉ុត មិនពិតទេ ព្រោះកូនក្តីខ្លួនមិនបានសុំដីគាត់នៅទេ។ គណៈកម្មការសុរិយោដីតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់ជាតិ បានចេញសេចក្តីសំរេចថា ដីទំហំ ១៩៨ម$^2$ ជាដីចំណីផ្លូវ។ ឈ្មោះ [redacted] សារ៉ុត បានប្តឹងទាមទារដីទាំងមុខ និង ដីខាងក្រោយ។

**សំណូមពរ :** សុំសំរេចតម្កល់តាមការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

១៥៨
3

Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និង សេចក្តីសន្និដ្ឋាន

របស់មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២១៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] យ៉ុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ ដែលសំរេចបង្វិលសំណុំរឿងនេះ ទៅគណៈកម្មការសុរិយោដីវិញនោះ គឺជាការភ័ន្តច្រលំ ព្រោះថា នៅក្នុងករណីនេះ គណៈកម្មការសុរិយោដីបានពិនិត្យអំពីកម្មវត្ថុបណ្តឹងរបស់ដើមចោទ និង ចុងចម្លើយរួចហើយ ហើយសេចក្តីសំរេចរបស់គណៈកម្មការនេះក៏បានចូលជាស្ថាពរហើយដែរ ម្យ៉ាងវិញទៀត ដើមចោទមិនបានប្តឹងមកតុលាការដើម្បីបដិសេធសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទេ។ ដូច្នេះ តុលាការមានសមត្ថកិច្ចបន្តក្នុងការពិនិត្យ និង សំរេចលើសំណុំរឿងនេះ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១១ "ក្រ.Ⅱ.សវ" ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ ពុំត្រឹមត្រូវតាមគតិច្បាប់ទេ។

### ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២១៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] យ៉ុន ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ១១ "ក្រ.Ⅱ.សវ" ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ២១៤ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកាឆ្នាំ ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

Scanned with CamScanner

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ ដើមចោទ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៤

ប្រធាន

[redacted]



Scanned with CamScanner